# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាចូលឆ្នាំវៀតណាម
# ចំប៉ា ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩
# ឲ្យយើងរស់នៅក្នុងធម៌មេត្តាករុណា

**អត្ថបទទី១៖ ហេប្រឺ ១២,៤-៧.១១-១៥**

បងប្អូនស៊ូទ្រាំនឹងការប្រដៅបែបនេះ មកពីព្រះជាម្ចាស់រាប់បងប្អូនថាជាកូន។ តើមានកូនណា ដែលឪពុកមិនវាយប្រដៅ? ហាប ១២,៧

**ដំណឹងល្អ៖ ម៉ាកុស ៦,១-៦**

ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ធម្មតា គេមើលងាយព្យាការី*តែក្នុងស្រុកកំណើត ក្នុងក្រុមគ្រួសារ និងក្នុងផ្ទះរបស់លោកប៉ុណ្ណោះ»។ មក ៦,៤

បងប្អូនជាទីស្រឡាញ់!

**" កុមារាកុមារី ចូរស្តាប់បង្គាប់មាតាបិតា ដោយយល់ដល់ព្រះអង្គម្ចាស់ធ្វើដូច្នេះទើបត្រឹមត្រូវ"** ចូរគោរពឪពុកម្តាយ ស្តាប់បង្គាប់ឪពុកម្តាយ។ ម្សិលមិញយើងបានអធិដ្ឋានសម្រាប់ជីវិតរបស់យើង ថ្ងៃនេះយើងអធិដ្ឋានសម្រាប់គ្រួសាររបស់យើង ថ្ងៃស្អែកយើងអធិដ្ឋានសម្រាប់ការងារឲ្យយើងរកស៊ីជោគជ័យក្នុងជីវីត។ ប៉ុន្តែ តាមពិតទាំងបីថ្ងៃ គឺជាជីវិតរបស់យើងទាំងស្រុង ដោយដឹងថានៅពេលយើងចូលនៅក្នុងឆ្នាំថ្មីយើងទូលអង្វរព្រះជាម្ចាស់ ប្រទានពរដល់ជីវិតរបស់យើងផ្ទាល់។ ដោយសារយើងមិនមែនជាគ្រីស្តបរិស័ទនៅពេលយើងចូលព្រះវិហារ ប៉ុន្តែថ្ងៃចូលឆ្នាំជាឱកាសមួយ ដើម្បីឲ្យយើងនឹកឃើញព្រះពរដែលយើងសុំពីព្រះជាម្ចាស់ ដើម្បីបំភ្លឺជីវិតរបស់យើងទាំងស្រុង ជីវិតរបស់យើងប្រចាំ ជីវិតរបស់យើងជាគ្រួសារ ជីវិតរបស់យើងជាអ្នកធ្វើការ ជីវិតរបស់ជាកូនក្មេង ជីវិតរបស់យើងជាអ្នកត្រូវរៀននៅសាលា រកស៊ីក៏ដោយ ចូលនិវត្តន៍ក៏ដោយ ទោះឈឺក៏ដោយ។ ព្រះជាម្ចាស់ បានប្រទានជីវិតដើមដំបូង ណែនាំឲ្យយើងទាំងអស់ដែលជាគ្រីស្តបរិស័ទនៅក្នុងព្រះសហាគមន៍ អាចរួមរស់នៅក្នុងសេចក្តីសុខសាន្តលុះត្រាតែ យើងផ្ញើជីវិតរបស់យើងទៅលើព្រះជាម្ចាស់ ដោយនឹកឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលយើងស្តាប់នៅក្នុងព្រះវិហារដើម្បីអនុវត្តន៍ក្នុងជីវិតរៀងរាល់ថ្ងៃ។

កុមារាកុមារីចូរស្តាប់មាតាបិតា រីឯបងប្អូនដែលជាឪពុកវិញកុំធ្វើឲ្យកូនរបស់ខ្លួនមួម៉ៅ គឺឪពុកម្តាយត្រូវការធ្វើយ៉ាងណាឲ្យកូនផ្ទាល់ខ្លួន ពោរពេញដោយសេចក្តីសុខ ដើម្បីរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងជីវិត នៅក្នុងជំនឿ នៅក្នុងសេចក្តីស្រឡាញ់ នៅក្នុងចំណេះដឹង ដើម្បីទៅថ្ងៃអនាគតទៅជាកូនពោរពេញដោយសុភមង្គល។ ពេលចូលនៅក្នុងព្រះវិហារ យើងឃើញគ្រប់អាយុជួបជុំគ្នាក្នុងព្រះវិហារតែមួយ នេះជាសញ្ញាសម្គាល់នៃក្រុមគ្រួសារដែលយើងគោរពថ្ងៃ

នេះ។ ក្រុមគ្រួសារមិនមែនតែឪពុកម្តាយនឹងកូន ប៉ុន្តែក្រុមគ្រួសារមានលោកតាលោកយាយ បុព្វបុរសរបស់យើងដែលយើងគោរពថ្ងៃនេះ រហូតដល់កូនចៅដែលអង្គុយនៅទីនេះ ឲ្យយើងដឹងថានេះគឺជាគ្រួសារដ៏អស្ចារ្យដែលព្រះជាម្ចាស់បានរៀបចំ។ សម័យដើម ដើម្បីណែនាំឲ្យជីវិតនៃព្រះសហគមន៍ ទៅជាជីវិតពោរពេញដោយសេចក្តីស្រឡាញ់ ដោយសារយើងនឹកឃើញនៅពេលព្រះយេស៊ូបានប្រសូតជាមនុស្ស ព្រះយេស៊ូបានប្រសូតនៅក្នុងគ្រួសារមួយ ដែលមានឪពុកម្តាយ(លោកយ៉ូសែបនិងព្រះនាងម៉ារី) ប៉ុន្តែគេមានលោកតាលោកយាយដែរ (លោកយាយហាណានិងលោកតាយ៉ូហាគីម) ដែលជាឪពុកម្តាយរបស់ព្រះនាងម៉ារី។

ប៉ុន្មានថ្ងៃមុន យើងបានគោរពបុណ្យថ្វាយព្រះឱរសយេស៊ូទៅព្រះវិហារយេរ៉ូសាឡឹម ហើយនៅពេលនោះយើងឃើញលោកតាលោកយាយពីររូបទៀត លោកតាស៊ីមីអុនដែលបានទន្ទឹងរង់ចាំអស់មួយជីវិតរបស់គាត់ ដើម្បីមើលផ្ទាល់ភ្នែករបស់គាត់ការសង្គ្រោះគឺព្រះយេស៊ូផ្ទាល់។ នៅពេលនោះមានយាយហាណាម្នាក់ទៀត ជាព្យាការីម្នាក់ដែលទន្ទឹងរង់ចាំមើលការសង្គ្រោះដែរ។ បើយើងចាប់អារម្មណ៍ អំពីដំណើរនៃការសង្គ្រោះក្នុងសម្ពន្ធមេត្រីចាស់ និងសម្ពន្ធមេត្រីថ្មី នៅក្នុងគម្ពីរដំណឹងល្អ យើងឃើញក្រុមគ្រួសារសំខាន់ណាស់ ពីលោកតាអាប្រាហាំដែលមានកូនចៅយ៉ាងច្រើនរហូតដល់យ៉ូហាគីម និងហាណា ស៊ីមីអុននិងហាណាដែលជាលោកតាលោកយាយបុព្វបុរស ដែលទទួលស្វាគមន៍ព្រះនាងម៉ារីនិងលោកយ៉ូសែប ដែលបានស្វាគមន៍ព្រះយេស៊ូ។ យើងនឹកឃើញដល់អេលីសាប៊ែត និងហ្សាការីដែលបានស្វាគមន៍យ៉ូហានបាទីស្ទ នេះទាំងអស់ដែលជាក្រុមគ្រួសារដ៏អស្ចារ្យ។

ថ្ងៃនេះ ដែលយើងគោរពបុព្វបុរសរបស់យើង យើងត្រូវការនឹកឃើញដើម្បីកសាងព្រះសហគមន៍របស់ព្រះគ្រីស្ត ដើម្បីកសាងសង្គមប្រកបដោយសេចក្តីសុខសាន្ត យើងធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះសហគមន៍របស់យើង ទៅជាក្រុមគ្រួសារដែលចេះស្រឡាញ់គ្នាទៅវិញទៅមក។ នៅពេលយើងអង្គុយដូចនេះ យើងឃើញក្រុមគ្រួសារដែលចេះសហការគ្នា ដែលចេះស្រឡាញ់គ្នាដោយសារព្រះយេស៊ូ។ ប៉ុន្តែ ពេលយើងទៅតាមផ្ទះឲ្យយើងបន្តរស់នៅក្នុងសេចក្តីស្រឡាញ់ដែលយើងបានទទួលនៅពេលអភិបូជា ឲ្យយើងបន្តរស់នៅក្នុងក្រុមគ្រួសារមួយដែលចេះគោរពគ្នាទៅវិញទៅមក លើកលែងទោសឲ្យគ្នាទៅវិញទៅមក។ ហេតុនេះហើយ ពេលយើងចូលក្នុងព្រះវិហារយើងបានទទួលច្រើន ពេលយើងចេញពីវិហារឲ្យយើងរស់នៅតាមបរិយាកាសហ្នឹងដោយសារព្រះយេស៊ូកើតជាមនុស្ស នៅក្នុងក្រុមគ្រួសារមួយ ព្រះយេស៊ូបានណែនាំឲ្យព្រះសហគមន៍ទៅជាក្រុមគ្រួសារមួយយ៉ាងធំ ដែលរស់នៅក្នុងសង្គមបច្ចុប្បន្ននេះ ណែនាំសង្គមរបស់យើងរកឃើញសេចក្តីសុខ។

យើងដឹងហើយក្រុមគ្រួសារជាសង្គមដ៏តូចមួយ ក្រុមគ្រួសារជាព្រះសហគមន៍ដ៏តូចមួយ តាមផ្ទះរបស់យើងនីមួយៗយើងមានរូបសន្តយ៉ូសែប រូបព្រះនាងម៉ារី រូបសម្ដេចប៉ាប និងរូបលោកឪពុកហៀបក៏មានដែរ។ យើងដូចជាមានអាសនៈតូចមួយ ដើម្បីណែនាំឲ្យគ្រួសារយើងអធិដ្ឋានឲ្យយើងដឹងថាគ្រួសារខ្ញុំមានក្ដីសុខ ដោយសារនៅក្នុងផ្ទះខ្ញុំយកចិត្តទុកដាក់អធិដ្ឋានជាមួយឪពុកជាមួយម្ដាយ ជាមួយលោកតា ជាមួយលោកយាយ ជាមួយកូន។ នេះជាគ្រួសារមួយដែលមានសេចក្ដីសុខ ដោយសារនៅតាមផ្ទះយើងចេះជួបជុំគ្នានៅមុខអាសនៈ ដែលយើងបានរៀបចំដើម្បីអធិដ្ឋាន។ នៅពេលអធិដ្ឋាន យើងនឹកឃើញធ្វើយ៉ាងម៉េចរស់នៅនៅក្នុងសេចក្ដីស្រឡាញ់ ដោយសារព្រះយេស៊ូយាងមកដើម្បីណែនាំឲ្យយើងទាំងអស់ ពោរពេញដោយសេចក្ដីស្រឡាញ់។ អត្ថបទដែលយើងធ្លាប់ស្ដាប់ "**លោកប៉ូលបានរំលឹកយើងធ្វើការងារអស្ចារ្យ យើងធ្វើជាមនុស្សដែលមានស្នាដៃច្រើន ប្រសិនបើយើងអត់មានសេចក្ដីស្រឡាញ់ទេ ការងារដែលយើងធ្វើ ស្នាដៃដែលយើងមាន បីដូចជាអត់មានអត្ថន័យសោះ ដូចជាអត់មានតម្លៃសោះ**"។ សេចក្ដីស្រឡាញ់ ជាអ្វីដែលស្ថិតស្ថេរលើសពីជំនឿ លើសពីសេចក្ដីសង្ឃឹម។

ប្រសិនបើយើងរស់នៅ នៅក្នុងសេចក្ដីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ ពីមួយថ្ងៃទៅមួយថ្ងៃយើងដឹងថា ឆ្នាំថ្មីនេះយើងធ្វើយ៉ាងម៉េចដើម្បីឲ្យយើងដឹងថា ឆ្នាំនេះជាឆ្នាំមហាករុណាទិគុណម្ដងទៀត។ មានន័យថា ឆ្នាំនេះជាឆ្នាំដែលព្រះជាម្ចាស់យាងមកដើម្បីណែនាំឲ្យយើងពោរពេញដោយធម៌មេត្តាករុណារបស់ព្រះអង្គ។ យើងរស់នៅដោយសុំព្រះជាម្ចាស់ប្រទានពរដើម្បីឲ្យមួយឆ្នាំទៅមួយឆ្នាំ ទៅជាឆ្នាំមហាករុណាទិគុណ ដោយសារពេលព្រះយេស៊ូយាងចូលនៅក្នុងវិហារកាផានំ ព្រះយេស៊ូចាប់ផ្ដើមទេសនាដោយអានអត្ថបទអេសាយ **ឆ្នាំនេះជាឆ្នាំមហាករុណាទិគុណ នៅពេលនេះទៅជារូបរាងយ៉ាងពិតប្រាកដ**។ ឆ្នាំនេះឲ្យយើងអធិដ្ឋានសម្រាប់គ្រួសារយើង សម្រាប់ព្រះសហគមន៍យើង សម្រាប់ប្រទេសយើងឲ្យយើងរស់នៅក្នុងធម៌មេត្តាករុណាឆ្នាំនេះ ដើម្បីឲ្យយើងពោរពេញដោយសេចក្ដីសុខ សម្រាប់គ្រួសារយើង ជីវិតយើង ភូមិរបស់យើង នឹងព្រះសហគមន៍របស់យើង។ អាម៉ែន៕